អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

**សកម្មភាព** ៖ **ល្បែងនិទានរឿងសារឡើងវិញ**

**ចិត្តចលភាព**

បំណិនចលកតូច (ការហ្វឹកហាត់បង្កើនកម្លាំង ងសម្របសម្រួលសាច់ដុំដៃនិងភ្នែកសាច់ដុំភ្នែក)

បំណិនចលកធំ (ការហ្វឹកហាត់បង្កើនកម្លាំង និងសម្របសម្រួលសាច់ដុំតូច និងសាច់ដុំធំ)

**ភាសាខ្មែរ**

ស្តាប់ (ស្តាប់គេនិយាយ និងមានសម្ថភាពស្តាប់ដោយធ្វើតាម)

ការស្គាល់តួរអក្សរ (ការយល់ដឹងពេញចិត្តអំពីការអាន និងការប្រើប្រាស់ឯកសារសំណេរ ឬ ឯកសារផ្សេងៗ)។

**គោលបំណង**

**(ចិត្តចលភាព)** ប្រាប់ពីរបៀបធ្វើចលនាតាមបែបទម្រង់ផ្សេងៗ ដោយការធ្វើអ្វីមួយ ឬ ការលេងល្បែងផ្សេងៗ។

ប្រាប់ពីការដើរ ឬ លើសពីនេះទៅតាមទម្រង់នៃសកម្មភាពផ្សេងៗ។

**(ភាសាខ្មែរ)** ប្រាប់បានខ្លះពីដំណើររឿង តាមរយះរូបភាពដែលបានបង្ហាញ ឬ សួរសំណួរ។

ប្រាប់ពីសកម្មភាពតាមដំណាក់កាលដោយអនុវត្តតាមការណែនាំ។

ប្រាប់ពីរបៀបបើកសៀវភៅរឿងនិទានពីស្តាំទៅឆ្វេងមិនរំលងទំព័រ និងអានតាមរូបភាព។

**រយះពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ រូបភាពសខ្មៅក្នុងសៀវភៅមួយ (មួយសន្លឹកម្នាក់)

**ការរៀបចំ** ៖ បោះពុម្ភក្រដាសរូបភាពឱ្យក្មេងម្នាក់ ១សន្លឹកៗ។ តែប្រសិនបើមានក្មេងៗច្រើនពេកនោះ អ្នកត្រូវឱ្យក្មេង ២នាក់មានក្រដាសរូបភាពដូចគ្នា។ប៉ុន្តែឱ្យក្រដាសរូបភាពម្នាក់មួយសន្លឹកៗ។

**សេចក្តីណែនាំ៖**

ចំណាំ ៖ សកម្មភាពនេះអាចលេងបានទាល់តែមានការអានសៀវភៅបានច្រើនដងតែប៉ុណ្ណោះ ប៉ុន្តែបើអត់ទេ អ្នកត្រូវមើលសេចក្តីណែនាំមួយចំនួនដូចខាងក្រោម។

1. និទានរឿងដែលយកមកលេងល្បែងនេះឱ្យកុមារបានប្រាប់ម្តងទៀត

2. ចែកក្រដាសរូបភាពទំព័រសៀវភៅឱ្យទៅក្មេងៗម្នាក់ ១សន្លឹក ឬ១សន្លឹក២ទៅ៣នាក់ក៏បានដែរ ទៅតាមចំនួនកុមារនៅក្នុងថ្នាក់របស់អ្នក។
(ឧទាហរណ៍សៀវភៅមាន១០ទំព័រ ប៉ុន្តែសិស្សមាន២០នាក់យើងអាចចែក២នាក់មួយទំព័រក៏បានដែរ)
3. ឱ្យក្មេងៗមើលទៅរូបភាពក្នុងសៀវភៅ ដែលអ្នកអាននឹងកំពុងបង្ហាញ។
4. កុមារទាំងអស់ដែលបានសន្លឹកទំព័រហើយ ត្រូវឈរនៅខាងមុខទាំងអស់ជាជួរតាមលំដាប់លំដោយទំព័រសៀវភៅរឿង និងបង្ហាទំព័ររបស់ក្រុមខ្លួន។ ចូរកូននិយាយពីអ្វីដែលមានក្នុងសៀវភៅនៃទំព័រដើមឱ្យមិត្តរួមថ្នាក់ស្តាប់? ដើម្បីបង្ហាញទំព័រសៀវភៅឱ្យមិត្តរួមថ្នាក់បានឃើញ។
5. បន្តការនិទានរឿងតាមទំព័ររបស់ក្រុមខ្លួនរហូតដល់ចប់រឿងហ្នឹងជាការស្រេច។
6. ល្បែងនេះគ្រាន់តែចង់ឱ្យកុមារបានចងចាំ និងអាចនិទានសាច់រឿងដែលពួកគេបានស្តាប់តែប៉ុណ្ណឹង។